# ការចិញ្ចឹមដង្កូវនាងអឺរី (ERI-SILKWORM)



*រៀបចំដោយ លោក តាល់ មករា ជំនួយការ មជ្ឈមណ្ឌល កសិកម្មសមស្រប - CSA សាកលវិទ្យាល័យភូមិន្ទកសិកម្ម*

ដង្កូវនាងអឺរី (philosamia ricini) គឺជាដង្កូវនាងពូជព្រៃដែលស៊ីស្លឹករុក្ខជាតិ ដូចជា ល្ហុងប្រេង ដំឡូងមី ។ នៅក្នុងផលិតកម្ម សំបុករបស់ដង្កូវនាងពូជនេះត្រូវបានគេយកទៅធ្វើជាក្រណាត់ គ្រឿងសំអាង និងវត្ថុតាំងលម្អផ្សេងៗ។ ដឹកដឿរបស់ដង្កូវនាងនេះ អាចហូបបាន និងអាចយកធ្វើជាចំណីសត្វដ៏ល្អព្រោះវាមានប្រូតេអ៊ីនខ្ពស់ ។ សីតុណ្ហភាពដែលប្រសើរបំផុត សម្រាប់ដង្កូវនាងពូជនេះ គឺ ២៦-២៨ អង្សាសេ ហើយសំណើមគឺ ៧៥ - ៩០ ភាគរយ ។ ប៉ុន្តែ វាក៏អាចរស់បានដែរ នៅសីតុណ្ហភាព និងសំណើមទាប ឬខ្ពស់ជាងនេះ ។



នៅប្រទេសកម្ពុជាយើង ដំណាក់កាលដង្កូវ ដល់ឡើងរុំសំបុកមានរយៈពេល ១៣ - ១៥ ថ្ងៃ ។ នៅពេលដែលសីតុណ្ហភាពទាប ការលូតលាស់របស់វា ក៏មានរយៈពេលយូរ ផ្ទុយមកវិញ នៅពេលដែលសីតុណ្ហភាពឡើងខ្ពស់ (៣០ - ៣៥ អង្សាសេ) អាយុកាលនៃការលូតលាស់របស់វាក៏មានរយៈពេលខ្លី ។



ជាទូទៅ នៅដំណាក់ដង្កូវចែកជា ៥ វគ្គ គឺវគ្គទី ១ មានរយៈពេល ៣-៤ ថ្ងៃ វគ្គទី២ មានរយៈពេល ៣-៤ ថ្ងៃ វគ្គទី ៣ មានរយៈពេល ៣-៤ ថ្ងៃ វគ្គទី ៤ មានរយៈពេល ៤-៥ ថ្ងៃ និងវគ្គទី ៥ មានរយៈពេល ៤-៥ ថ្ងៃ ។ ដំណាក់កាលរុំសំបុកមានរយៈពេល ៣ ថ្ងៃ ដំណាក់កាលដឹកដឿមានរយៈពេល ៧ ថ្ងៃ ដំណាក់កាលមេអំបៅមានរយៈពេល ៣ ថ្ងៃ និងដំណាក់កាល ស៊ុត មានរយៈពេល ៩ ថ្ងៃ ។

ដង្កូវនាងអឺរី ត្រូវចិញ្ចឹមនៅក្នុងផ្ទះ ដែលមានពន្លឺ និងខ្យល់ចេញចូលគ្រប់គ្រាន់ ប៉ុន្តែមិនត្រូវឲ្យមានពន្លឺថ្ងៃចាំងមកផ្ទាល់នោះទេ ។ កន្លែងចិញ្ចឹម ត្រូវតែស្អាតមានអនាម័យល្អ ហើយត្រូវនៅឲ្យឆ្ងាយពីសារធាតុគីមី និងផ្សែងពុល ។

ការចិញ្ចឹមដង្កូវនាងអឺរីមានលក្ខណៈសាមញ្ញដែលមិនទាមទារនូវអ្នកបច្ចេកទេសជំនាញនោះទេ។ ដើម្បីជោគជ័យក្នុងការចិញ្ចឹម អ្នកចិញ្ចឹមត្រូវតែ មានចំណីគ្រប់គ្រាន់ ការថែទាំ ដោយរក្សាសំណើម ពន្លឺ និងខ្យល់ចេញចូលឲ្យបានស្រមស្រប ។